# រឿង ភាសាថ្ម

# IF THE STONES COULD SPEAK

Children book.indd 2 7/12/06 4:11:05 PM

Heritage Watch
Preserving the Past... Enriching the Future.

At this very moment, looters around the world are reducing countless ancient sites to rubble in the pursuit of buried treasure. Few countries are more threatened than Cambodia, the heart of the ancient Khmer Empire. Cambodia's heritage is being destroyed at an unprecedented rate — entire temples have been hacked apart by looters seeking prized statues to sell on the international art market. With each plundered artifact smuggled out of the country, untold knowledge of the past is lost.

This alarming destruction prompted a group of international scholars to form HeritageWatch, a non-profit organization working since 2003 to protect Cambodia's great archaeological resources. Since the antiquities trade survives largely on ignorance — of those who loot and buy antiquities — education is at the heart of our efforts. We hope you enjoy this book, and take its message to heart. The antiquities trade is destroying Cambodia's great past, and risking its future, but you can do your part to help! Looting is driven by demand. By refusing to purchase looted antiquities you are helping to end this demand.

To learn more about HeritageWatch and what you can do to stop the illicit antiquities trade, go to www.heritagewatch.org.

Children book.indd 3 7/12/06 4:11:20 PM

អង្គការគាំពារកេរ្តិ៍មរតកជាអង្គការក្រៅរដ្ឋាភិបាលមួយបង្កើតឡើងនៅឆ្នាំ២០០៣ដែលមានសកម្មភាពនិងគោលបំណងចូលរួមចំណែកក្នុងការថែរក្សាសម្បត្តិវប្បធម៌ជាតិខ្មែរ។ ដោយឃើញមានការបំផ្លាញសម្បត្តិវប្បធម៌ខ្មែរគួរឱ្យកត់សម្គាល់ និង ឈានទៅដល់ការលក់សម្បត្តិទាំងនោះព្រោងព្រាតនៅលើទីផ្សារអន្តរជាតិនិងតាមអ៊ីនធឺណែតជាហេតុធ្វើឱ្យមានការព្រួយបារម្ភជាខ្លាំងពីសំណាក់អ្នកស្រាវជ្រាវជាតិ និង អន្តរជាតិ។ បើសិនជាសម្បត្តិទាំងនោះត្រូវគេធ្វើចរាចរខុសច្បាប់ចេញពីប្រទេសខ្មែរ អតីតកាលរបស់ខ្មែរយើងនឹងត្រូវបាត់បង់ ព្រោះថាសម្បត្តិទាំងនោះជាភស្តុតាងយ៉ាងសំខាន់ដែលបញ្ជាក់ពីប្រវត្តិសាស្ត្រ និង អត្តសញ្ញាណជាតិខ្មែរ។

សៀវភៅអប់រំរឿង " វាចាថ្ម " បានរៀប រៀងឡើងដោយអង្គការគាពារកេរមរតក ដើម្បីផ្សាព្វផ្សាយដលសិស្សានុសិស្ស ព្រមទាំងប្រជាពលរដ្ឋទូទៅឱ្យចេះស្រលាញ់ និង ចូលរួម ថែរក្សាសម្បត្តិវប្បធម៌ជាតិដែល បន្សល់ទុកពីដូនតាឱ្យនៅគង់វង្សសម្រាបជាប្រយោជន៍ដល

ប្រជាជន ខ្មែរទាំងអសគ្នា។

# IF THE STONES COULD SPEAK

# រឿង ប្រសិនបើថ្មចេះនិយាយ

គាំពារកេរមរតកសង្ឃឹមថា ខ្លឹមសារសំខាន់នៃសាច់រឿងនេះ នឹងធ្វើឱ្យសិស្សានុសិស្ស និង ប្រជាជនតាមសហគមន៍យល់ដឹងនិងចាប់អារម្មណ៍ដល់កិច្ចខិតខំប្រឹងប្រែងអភិរក្សសម្បត្តិវប្បធម៌មានក្នុងមូលដ្ឋានរបស់ខ្លួនកុំឱ្យឈ្មួញទុច្ចរិតកេងចំណេញលើសម្បត្តិវប្បធម៌ខ្មែរ ព្រោះសម្បត្តិទាំងនោះជារបស់ខ្មែរគ្រប់រូបមិនមែនជាកម្មសិទ្ធរបស់បុគ្គលណាម្នាក់ឡើយ។ ការជួញដូរបុរាណជាអំពើល្មើសច្បាប់។

គាំពារកេរមរតកសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់លោក រូប៉ឺត្រ ដេវីស និង លោក ស្រី រេជីណា ដេវីស ដែលបានឧបត្ថម្ភដល់ការបោះពុម្ពសៀវភៅនេះ លោក ឈុន តាង ជួយខាងបច្ចេកទេសកុំព្យូទរ័ និង រចនាសៀវភៅទាំងមូល។



Children book.indd 4 7/12/06 4:11:32 PM

Long ago in a beautiful land there was a great city deep in the jungle. In this city were many temples, and all were guarded by magical statues carved from the rock of a sacred mountain.

Each statue was different. There was Apsara, a beautiful dancer who came from the heavens. There was Dvarapala, a giant who defended the temple gates with his powerful club. There was Naga, a water serpent with many heads who came from the underworld.

កាលពីដើមមានដែនដីដ៏ស្រស់បំព្រងមួយស្ថិតនៅព្រៃជ្រៅដែលសម្បូរទៅដោយប្រាសាទបុរាណជាច្រើននិងមានរូបចម្លាក់ឆ្លាក់វិលេចដោយក្បាច់រចនារស់រវើកជាច្រើន អនែកនៅតាមជញ្ជាំងថ្មនៃប្រាសាទមានរូបចម្លាក់ទោល ចម្លាក់លឹប និង ចម្លាក់លៀន ដូចជា៖ រូបទេពអប្សរជាអ្នករាំទន់ភ្លន់ស្រស់ស្អាតដូចទេពអប្សរចុះមកឋានសួគ៌។

រូបទ្វារបាល ជាអ្នកការពារតាមច្រកចេញចូលប្រាសាទដែលបង្ហាញពីភាពរឹងមាំ ខ្លាំងក្លា និង មានទឹកមុខប្រកបដោយអំណាចព្រមទាំងមានរូបចម្លាក់នាគក្បាលច្រើន ដែលស្ថិតនៅគ្រប់ទីសនៃច្រកចេញចូលប្រាសាទ។



But most magical of all was Garuda, the king of all birds. Garuda was part man and part bird. Though he had the body of a human, he had feathered wings, a massive beak, and the claws of an eagle.

Garuda was very happy in his temple. During the day, there were many monks studying the teachings of the Buddha. The monks were very kind, and treated everyone and everything with respect. From the monks, Garuda learned that if he did good deeds, he would gain merit and be rewarded.

ក្នុងនោះមានចម្លាក់ រូបគ្រុឌ ជាស្តេចសត្វបក្សីទាំងឡាយដែលមានខ្លួនជាមនុស្ស អមដោយស្លាបបក្សីនៅខ្នងមានចំពុះមាត់ធំមាំនិងមានក្រចករែងកោងដូចសត្វឥន្ទ្រីយ៍។

សត្វគ្រុឌនេះរស់នៅក្នុងប្រាសាទយ៉ាងសប្បាយរីករាយ ដោយនៅក្នុងប្រាសាទនេះមានព្រះសង្ឃមកសំដែងព្រះធម៌ជាញឹកញាប់ហើយព្រះសង្ឃគ្រប់អង្គ មានទឹកចិត្តជ្រះថ្លាសប្បុរសដល់អ្នកគ្រប់ៗគ្នានិងរក្សាទុករាល់របស់ផ្សេងៗនៅក្នុងប្រាសាទដោយការគោរពយ៉ាងជ្រាលជ្រៅ។

តាមរយៈការសំដែងធម៌របស់ព្រះសង្ឃធ្វើឱ្យគ្រុឌយល់ថា ប្រសិនបើយើងសាងអំពើល្អ យើងនឹងទទួលបុណ្យកុសលល្អទៅតាមនោះដែរ។



At night, Garuda would teach the other statues what he learned. He said that they must listen to the monks, and follow their example.

"But the monks will be leaving soon!" said Naga. "The snakes told me the great city is being abandoned, many people have already left!"

"I do not believe you!" said Garuda. But he asked the birds — who see everything — and learned that Naga was right.

"How can the people abandon us?" asked Dvarapala. "They need us! Who else will notify the gods when the people need their prayers to be answered?"

"I don't know," cried Apsara. "What a sad life it will be for us! And sad for the people as well, without statues to protect them."

The monks did go. Many years passed. The temple walls crumbled, great trees grew up amidst the stones, and vines covered Garuda and the other statues. But Garuda never gave up hope that the people would return.

Then one day, the birds flew to Garuda and told him that they had seen men nearby!

នៅរាត្រីមួយគ្រុឌបានផ្សព្វផ្សាយឱវាទរបស់ព្រះសង្ឃទៅដល់រូបចម្លាក់ដទៃទៀតនៅក្នុងប្រាសាទ។ យើងរាល់គ្នាគួរស្តាប់ឱវាទព្រះសង្ឃ និង ប្រព្រឹត្តគោរពទៅតាមព្រះពុទ្ធជាទីសក្ការៈដើម្បីឱ្យពួកយើងជួបតែសេចក្ដីសុខ។

នាគ៖ ព្រះសង្ឃទាំងនោះនឹងចាកចេញពីពួកយើងពីព្រោះខ្ញុំបានដំណឹងនេះពីសត្វពស់ ហើយគេថែមទាំងនិយាយទៀតថាតំបន់ប្រាសាទនេះ នឹងត្រូវគេបោះបង់ចោលជាមិនខាន។ មនុស្សម្នាជាច្រើនបានចាកចេញពីទីនេះអស់ហើយ!,

គ្រុឌ៖ ខ្ញុំមិនជឿងងទេ!! ខ្ញុំនឹងទាក់ទងសួរពពួកសត្វចាបឱ្យប្រាកដពីរឿងនេះ។ ក្រោយមក ទើបដឹងថាអ្វីដែលនាគនិយាយនោះជាការពិត។

ទ្វារបាល៖ ហេតុអ្វីបានជាប្រជាជននាំគ្នារត់ចេញពីទីនេះដូច្នេះ? ប្រជាជនគោរព និង ជឿលើប្រាសាទនេះណាស់!! តើមានអ្វីកើតឡើងទេដឹង?

ទេពអប្សរ៖ ទេពអប្សរស្រែកឆ្លើយទាំងស្រងូតស្រងាត់ទៅប្រាប់ទ្វារបាលថា ខ្ញុំក៏មិនដឹងដែរ។ ជីវិតតែងតែជួបប្រទះទុក្ខព្រួយជានិច្ច! តើជីវិតពួកយើងនិងអ្នកភូមិនឹងទៅជាយ៉ាងណា!!! ហើយតើគ្មាននរណាអាចជួយយើងបានទេឬ?

ជាច្រើនឆ្នាំកន្លងផុតទៅ! អ្នកភូមិនិងព្រះសង្ឃបានចាកចេញទៅបន្សល់ទុកនៅតែប្រាសាទបុរាណ។ ចំណែកជញ្ជាំងប្រាសាទទទួលរងនូវការបែកបាក់ដួលរលំស្ទើរគ្មានសល់និងមានដើមឈើធំៗដុះចាក់ឬសពុះជ្រែកថ្មប្រាសាទរួមទាំងវល្លិ៍លូតរុំព័ទ្ធលើគ្រុឌ និង រូបចម្លាក់ផ្សេងៗទៀត។ គ្រុឌនៅតែសង្ឃឹមជានិច្ចថានឹងមានមនុស្សម្នាវិលត្រឡប់មករស់នៅទីនេះវិញជាមិនខានឡើយ។ មិនយូរប៉ុន្មាន ថ្ងៃមួយ សត្វបក្សីបាននាំពាក្យមកប្រាប់គ្រុឌ ដោយពួកគេជួបប្រទះឃើញមនុស្សនៅក្បែរៗនោះ!

Children book.indd 9 7/12/06 4:12:00 PM



Children book.indd 10 7/12/06 4:12:03 PM

"The people are back!" Garuda shouted. "And they will make offerings at the temple! And they will give us their prayers to send on to the gods! We will be useful again!"

Suddenly, the men appeared, having hacked their way through the dense jungle surrounding the temple. They looked nothing like the monks—their skin was a different color, they had hair on their heads, and they wore strange clothing. But Garuda was too happy to care.

The strange men explored the temple, but they made no offerings and they said no prayers. Finally, they stopped in front of Apsara. She was overjoyed—it had been a long time since anyone had admired her beauty, and she was proud to be the first statue they noticed.

But her happiness soon turned to terror. The men took out large axes, and began attacking her! They hacked her out of the temple wall, as the other statues looked on in horror, and then disappeared into the jungle with her.

The other statues didn't know what to do! Who were these people? Where were they taking her? Had she been badly hurt? Would they bring her back?

គ្រុឌឮដំណឹងនេះត្រេកអរខ្លាំងណាស់ហើយនឹកសង្ឃឹមថា មានមនុស្សមកគោរព នឹងថ្វាយដង្វាយផ្សេងៗដើម្បីបួងសួងសុំសេចក្តីសុខដូចមុនទៀត! យើងរាល់គ្នានឹងមានគេគោរពដូចមុនមិនខាន។ នឹកស្មានមិនដល់ពួកគេទាំងនោះជាមនុស្សចម្លែក ដែលបានកាប់ឆ្ការព្រៃចូលមកដល់ប្រាសាទ តែគ្រុឌមើលឃើញមនុស្សនោះមានរូបរាង ពណ៌សំបុរប្លែកមិនដូចព្រះសង្ឃ និង ថែមទាំងស្លៀកពាក់មិនដូចសាសន៍ខ្មែរ ហើយមានសក់ពណ៌ចំឡែកថែមទៀត។

ដល់ពេលជនចំឡែកទាំងនោះមកដល់ប្រាសាទ ពួកគេមិនបានសែនដង្វាយដល់ប្រាសាទទេ!! គេបែរជាឈរនៅចំមុខរូបទេពអប្សរ ហើយនិយាយសសើរតែពីរូបទេពអប្សរនេះថា ពិតជាស្រស់ស្អាតមែនមានភាពរសរវើកតែម្តង។ នាងទេពអប្សរសប្បាយចិត្តយ៉ាងខ្លាំងដែលពួកគេកោតសរសើរលើសម្រស់របស់នាងដូច្នេះ។ មួយសន្ទុះក្រោយមកការសប្បាយរបស់នាងរលាយសាបសូន្យអស់ពេលដែលពួកគេនាំគ្នាដាប់យករូបនាងចេញពីផ្ទៃជញ្ជាំងប្រាសាទដោយមានសំឡេងខ្លាំងៗបណ្តាលឱ្យញ័រឮដល់ចម្លាក់ផ្សេងទៀត។

បន្តិចក្រោយពីដាប់រួចហើយ ពួកគេក៏នាំនាងទេពអប្សរយកទៅបាត់ជារៀងរហូត។



Children book.indd 11 7/12/06 4:12:03 PM

Garuda sent the birds to find out. They quickly returned and said that many statues were being stolen by such men all over the jungle kingdom, and were never seen again.

Years and years passed, and neither Apsara nor the strange men ever returned. The statues were very sad for her, and very frightened that one day they might meet the same end.

But then something happened that made them momentarily forget the fate of Apsara.

A great war was being fought in the jungle. No one was safe. The animals were afraid, and had decided to run to safety. Since the statues could not run, they tried to hide themselves in the jungle as best they could.

It did not take long for the fighting to reach the temple. People were everywhere, and they were shooting at each other with strange weapons. Many were killed. The statues had never seen anything so terrible!





ដោយរូបចម្លាក់ផ្សេងៗទៀតនាំគ្នាឆ្ងល់ថា

តើពួកគេជានរណាហើយនាំនាងទេពអប្សរទៅណា?

តើពេលណាទើបគេនាំនាងត្រឡប់មកវិញហ្ន?

គ្រុឌបានប្រើបក្សីឱ្យហើរស្វែងរកមើលនៅកន្លែងផ្សេងៗទៀតតែមិនបានទទួលដំណឹងអ្វីទាល់តែសោះ។

មួយឆ្នាំទៅមួយឆ្នាំបានកន្លងផុតទៅទាំងនាងទេពអប្សរនិងមនុស្សចម្លែកទាំងនោះមិនឃើញត្រឡប់មកវិញសោះ។ រូបចម្លាក់ផ្សេងៗទៀតនាំគ្នាព្រួយអើយព្រួយពីសុខទុក្ខនាងទេពអប្សរ ដោយនឹកគិតថាថ្ងៃណាមួយពួកគេអាចមានវាសនាដូចនាងឬអត់?

ទុកព្រួយសោកសៅបានកើតឡើង ដោយស្រុកទេសជួបប្រទះនឹងសង្គ្រាម មានចម្បាំងជាហូរហែរ។ មិនថាតែប្រាសាទទេសូម្បីតែប្រជាជនក៏ទទួលរងទុក្ខ ព្រាត់ប្រាស់គ្រួសារ វិនាសហិនហោចទ្រព្យសម្បត្តិ ស្ទើរគ្រប់ទីកន្លែងមានភាពចលាចលវឹកវរដោយសារសង្គ្រាម សត្វព្រៃបក្សាបក្សីនាំគ្នាគេចខ្លួនបាត់អស់។ ប៉ុន្តែ អណោចអធមរូបចម្លាក់មិនអាចរត់ទៅកន្លែងណាបានទេ។ ដូចនេះ ពួកគេនាំគ្នាលាក់ខ្លួននៅក្នុងប្រាសាទរៀងៗខ្លួន។ មិនយូរប៉ុន្មាន ការប្រយុទ្ធគ្នាក៏រំកិលដល់ បរិវេណប្រាសាទមានមនុស្សពីរក្រុមផ្សេងពីគ្នានៅពួនគ្រប់កន្លែងតម្រង់កាណុងកាំភ្លើងដាក់គ្នាបាញ់សម្រុកយកឈ្នះរៀងៗខ្លួន ដោយយកទីតាំងប្រាសាទជាសមរភូមិ ប្រយុទ្ធរបស់ពួកគេ។ មានមនុស្សស្លាប់រាប់មិនអស់រូបចម្លាក់ទាំងអស់មិនដែលជួបប្រទះនឹងសភាពគួរឱ្យភ័យខ្លាចរន្ធត់ដូច្នេះទេពីមុនមក។

Garuda wanted to keep hidden, but he remembered the teachings of the monks, and that he must always help others if he could.

“We must help the people! It is our duty!” he told the other statues. “We can hide the people and protect them!”

Sure enough, many people hid in the temple, and were able to escape harm. After many hours, the fighting stopped, and the jungle was again quiet.

“I am so glad we helped the people!” Garuda said to his friends.

But his friends did not answer him. Naga and Dvarapala had both been blown apart by a massive blast during the fighting, and lay in pieces, shattered on the ground.

Garuda had never felt such sorrow. He was now all alone, in the crumbling ruins of his beloved temple.

“How can things get worse?” he asked himself.

គ្រុឌបាននឹកឃើញដល់ឱវាទរបស់ព្រះសង្ឃថាយើងត្រូវចេះជួយសង្គ្រោះគ្នាក្នុងគ្រាមានអាសន្ន។ អញ្ចឹងយើងនាំផ្លូវជួយមនុស្សទាំងនោះឱ្យចូលពួនក្នុងប្រាសាទដើម្បីឱ្យយើងអាចការពារពួកគេបាន!! នេះក៏ជាកាតព្វកិច្ចរបស់យើងដែរ។

ភ្លាមៗនោះប្រជាជនក៏នាំគ្នារត់ចូលទៅក្នុងប្រាសាទ។ គេចខ្លួនរួចពីគ្រោះថ្នាក់បានមួយរយៈក្រោយរហូតដល់ការប្រយុទ្ធគ្នាបានបញ្ចប់ហើយនៅក្នុងព្រៃក៏មានភាពស្ងប់ស្ងាត់ទៅវិញ។

គ្រុឌ៖ ខ្ញុំមានអារម្មណ៍សប្បាយចិត្តណាស់ បន្ទាប់ពីបានជួយមនុស្សទាំងនោះ!! តែរូបចម្លាក់ដទៃទៀតមិនបានឆ្លើយតបមកវិញឡើយ ពីព្រោះនាគ ទ្វារបាល រងរបួស ត្រូវអំបែងគ្រាប់មានបំណែកជាច្រើនធ្លាក់មកលើដី។ គ្រុឌនៅនិយាយតែឯងក្នុងប្រាសាទជាទីស្រលាញ់ហើយសួរខ្លួនឯងថា តើហេតុអ្វីបានជាហេតុការណ៍កើតឡើងអាក្រក់យ៉ាងនេះ?



But things did get worse. One day the birds came to Garuda and said, “Bad men are coming, and they want to steal you! Hurry and hide!” Garuda did as the birds said, and tried to hide himself in the jungle. But it did not take long for the men to find him.

“This statue will be worth a fortune!” said one man.

“Yes! We will have no trouble selling him!” said another.

ហេតុការណ៍អាក្រក់បានកើតឡើងមែនដូចការគិតរបស់គ្រុឌ!! ថ្ងៃមួយ ពួកបក្សីបាននាំដំណឹងមកប្រាប់គ្រុឌថាពួកមនុស្សអាក្រក់ទាំងនោះមក ទៀតហើយ!! គឺគេមានបំណងចង់នាំយក រូបបងគ្រុឌឯងទៅទៀតហើយ!! សូមបងឯងប្រយ័ត្នខ្លួនផង!!

ប៉ុន្តែ គ្រុឌដូចជាពុំមានអ្វីការពារនិងលាក់ខ្លួនបានសោះ ហើយគាត់ខំ ព្យាយាមលាក់ខ្លួនក្នុងព្រៃដែរ តែមិនយូរប៉ុន្មានពួកគេក៏រកគាត់ឃើញ។ ពួកគេនិយាយថារូបចម្លាក់នឹងនាំសំណាងអោយយើងមិនខាន។ យើងនឹង-អាចលក់រូបនេះបានយ៉ាងងាយ!

Children book.indd 18 7/12/06 4:12:29 PM



Children book.indd 17 7/12/06 4:12:25 PM

Then the men took out large axes, and began to hack away at Garuda. With each blow they chipped off more and more stone, until he was no longer connected to the temple. Garuda was in much pain, and he was terribly frightened. But more than anything he was very sad, as he knew he would never again see his temple, where he had once been so happy.

Garuda was locked in a dark wooden box. He knew he was being taken far away, but was too sad to care.

ក្រោយមកក្រុមមនុស្សទាំងនោះ បានយកឧបករណ៍ធំៗមកដាប់គាស់បំផ្លាញធ្វើយ៉ាងណាអោយតែយកគ្រុឌបាន។ ហើយពួកគេនាំយកគាត់ចេញពីប្រាសាទដោយសេរី។ គ្រុឌមានអារម្មណ៍ភ័យខ្លាចនិងឈឺចាប់ខ្លាំងណាស់!! គាត់បានស្រែកថ្ងូរតែឯង ហើយគិតថាគាតមិនអាចត្រឡប់មកឃើញប្រាសាទជាទីស្រឡាញ់របស់គាត់ម្តងទៀតទេ?

គាត់ត្រូវបានដាក់ក្នុងប្រអប់មួយបិទជិតងងឹតឈឺង។ គ្រុឌដឹងថាគេកំពុងនាំគាត់ទៅទីដ៏សែនឆ្ងាយហើយមើលទៅ។



Children book.indd 20 7/12/06 4:12:34 PM

After many days of bumpy traveling, the box was opened and daylight flooded in. Garuda was surrounded by many men in uniforms.

“This statue has been stolen!” said one of the men. “It is a good thing we opened this box. Otherwise this statue would have crossed the border and been lost forever!”

“Yes,” said another one of the men. “Now we can send him back where he belongs.”

Garuda was once again placed in a box and shipped a long way. But this time he was happy, because he knew he was going home.



Children book.indd 21 7/12/06 4:12:45 PM



បន្ទាប់ពីធ្វើដំណើរលើផ្លូវយ៉ាងរលាក់អស់ជាច្រើនថ្ងៃមក ស្រាប់តែប្រអប់នោះត្រូវបើក ភ្លាមនោះគ្រុឌកំពុងតែនៅទ័ព្ធជុំវិញដោយមនុស្សជាច្រើនដែលពាក់ឯកសណ្ឋាន។

បុរសម្នាក់បានផ្ទុះសម្លេងភ្ញាក់ផ្អើល អូ!! " រូបចម្លាក់នេះត្រូវបានគេលួច" សំណាងហើយដែលយើងបើកកេសនេះ! បើមិនដូច្នេះទេរូបចម្លាក់ដ៏ប្រណីតនេះនឹងត្រូវគេនាំឆ្លងចូលស្រុកគេហើយ។ វានឹងបាត់រហូតហើយ_ បុរសម្នាក់ទៀតបានតបថា " ប្រាកដហើយ "។

ឥឡូវនេះយើងអាចបញ្ជូនរូបនេះទៅកន្លែងដើមវិញ។

គេបិតកេសនោះវិញ រួចដឹកត្រឡប់ទៅវិញ ហើយគ្រុឌសប្បាយចិត្តខ្លាំងណាស់ ព្រោះគាត់ដឹងថាគាត់អាចត្រឡប់ទៅប្រាសាទជាទីស្រឡាញ់របស់គាត់វិញហើយ។

Children book.indd 22 7/12/06 4:12:53 PM

When the box opened, he didn't see his temple — he saw something even better! He saw his friends!

There was Naga and Devapala — and though they were still a bit cracked, they were once again whole! And Apsara was there too!

"I thought I would never see you again! Where are we?" Garuda cried out, happier than he had been in years.

"We are in a place called a museum!" said Apsara.

"Here we are safe," said Naga. "Many statues live here! And there are people here who look after us. They put me and Devapala back together again!"

"There are people here?" Garuda asked.

"Many people!" said Naga. "There are people who work here, who study us to learn about the past. And then there are many others who come here only to admire us!"

"I am back in my country with my friends! I am safe! And I am serving a purpose again! Only one thing could make me happier…" thought Garuda.

ដល់ពេលប្រអប់បើក!! គាត់មិនបានឃើញប្រាសាទជាទីស្រឡាញ់គាត់ទេ។ បែរជាឃើញ កន្លែងល្អស្អាតហើយបានជួបមិត្តភក្ដិចាស់ៗ ដូចជា៖ នាគ ទ្វារបាល ហើយនិងនាងទេពអប្សរជាដើម។ តែពួកគេទាំងនោះមានស្លាកស្នាមស្នើរពេញខ្លួនទាំងអស់។

គ្រុឌ៖ ខ្ញុំមិននឹកស្មានថាបានជួបអ្នកទាំងអស់គ្នានៅទីនេះសោះ!! តើទីនេះជាកន្លែងណា?

អប្សរ៖ យើងនៅក្នុងសារមន្ទីរជាតិណាបង!!

នាគ៖ ពួកយើងមានសុវត្ថិភាពហើយ! ហើយមានរូបចម្លាក់ជាច្រើនក៏នៅទីនេះដែរ។ មានមនុស្សនៅចាំថែរក្សាការពារពួកយើងទាំងអស់គ្នាទៀតផង។ ហើយពួកគេនឹងព្យាបាលរូបខ្ញុំ និង បងទ្វារបាលអោយមានសភាពដូចដើមឡើងវិញ។

គ្រុឌ៖ តើមានមនុស្សមកទីនេះច្រើនទេ?

នាគ៖ មានច្រើនណាស់!! ខ្លះគេមកសិក្សាស្រាវជ្រាវអំពីអតីតកាលរបស់យើង ខ្លះមកមើលយើងរួចថែមទាំងស្ញើចសរសើរយើងទៀតផង។

គ្រុឌ៖ គ្មានអ្វីដែលធ្វើអោយខ្ញុំសប្បាយចិត្តជាងពេលនេះទេ ខ្ញុំបានត្រឡប់មកស្រុកខ្ញុំវិញ និង ជួបមិត្តភក្ដិទាំងអស់គ្នា។ ខ្ញុំមានសុវត្ថិភាពហើយ! ហើយខ្ញុំនៅតែអាចរក្សាតួនាទីរបស់ខ្ញុំដូចដើមដដែល។

Children book.indd 23 7/12/06 4:12:57 PM



And then he saw the familiar orange robes of the monks, who had come to make offerings in front of the statues. And Garuda knew that all of his prayers had been answered.

វំពេចនោះ!! គាត់បានប្រទះឃើញព្រះសង្ឃចូលមកមើលក្នុងសារមន្ទីរនេះ ហើយធ្វើការបួងសួង និង ថ្វាយដង្វាយផ្សេងៗទៀតផងនៅមុខរូបចម្លាក់មួយចំនួន។ គ្រានោះគ្រុឌបាននឹកដល់កាល ដែលគាត់បន់ស្រន់វាពិតជាសក្តិសិទ្ធិ។

Children book.indd 26 7/12/06 4:13:03 PM



Heritage Watch

Preserving the Past... Enriching the Future.

# Special Thanks

This book would not have been possible without the support of Robert and Regina Davis, who generously funded both its production and distribution.

HeritageWatch would also like to thank Mr. Chhun Tang, who volunteered his services as a professional designer on this project and also Mr. Khun Samen, Director of the National Museum, who provided the idea for Khmer Title.

សៀវភៅនេះអាចលេចចេញជារូបរាងបានដោយមានការជួយឧបត្ថម្ភថវិកាពី លោក រ៉ូប៊ែត្រ ហើយ និង លោកស្រី រ៉ូប៊ែត្រ ដេវីស។

គាំពារកេរមរតកក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅផង ដែរដល់ លោក ឈុន តាង ដែលលោកបានស្ម័គ្រចិត្តជួយរចនាសៀវភៅរឿង ប្រសិនបើថ្មចេះនិយាយនេះឡើង និង លោក ឃុនសាមេន ដែលបានជួយជាគំនិតដល់ការដាក់ចំណងជើងរឿងនេះ។

គាំពារកេរមតរកសូមជូនពរឱ្យ អ្នកទាំងអស់ដែលបានរួមចំណែកជួយដល់ការរៀបរៀងសៀវភៅនេះ ជួបប្រទះតែសុខសេចក្តីសុខគ្រប់ប្រការ។



Heritage Watch

Preserving the Past... Enriching the Future.

www.heritagewatch.org

Children book.indd 1 7/12/06 4:11:01 PM